ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
អគ្គនាយកដ្ឋានសុរិយោដី និង ភូមិសាស្ត្រ

លេខ : ១៨៧ អ/សជ.ក

ភ្នំពេញ, ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៦

អគ្គនាយក នៃអគ្គនាយកដ្ឋានសុរិយោដី និង ភូមិសាស្ត្រ

ជំរាបមក

លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី គ្រប់ខេត្ត-ក្រុង

**កម្មវត្ថុ :** អំពីការអនុវត្តសាលក្រម ឬ សាលដីកាស្ថាពរ ពាក់ព័ន្ធនឹងការផ្ទេរអចលនវត្ថុ

**យោង :** - លិខិតលេខ ៣៣០ ក.យ.រប/០៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៦ របស់ក្រសួងយុត្តិធម៌

- ចំណារឯកភាពរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី ចុះថ្ងៃទី ០៤-០៥-២០០៦

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជំរាបលោក-លោកស្រី ជាប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ជ្រាបថា : ការអនុវត្តសាលក្រម ឬ សាលដីកាស្ថាពរ ដែលពាក់ព័ន្ធនឹងការផ្ទេរអចលនវត្ថុ និង សេចក្តីសំរេចផ្សេងៗរបស់តុលាការ ដែលភាគីអ្នកឈ្នះក្តីបានយកសាលក្រម ឬ សាលដីកាស្ថាពរទៅស្នើសុំផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុនោះ ចាំបាច់ត្រូវឱ្យភ្ជាប់មកជាមួយសាលក្រម ឬ សាលដីកាស្ថាពរ នូវកំណត់ហេតុអនុវត្តសាលក្រម ឬ សាលដីកានោះ ទើបអាចផ្ទេរជូនបាន ។ ក្នុងករណីភាគីឈ្នះក្តីពុំមានសំអាងណាមួយបញ្ជាក់ថាសាលក្រម ឬ សាលដីកាស្ថាពរនោះត្រូវបានអនុវត្តដោយតុលាការទេ ជំនាញសុរិយោដីមិនអាចធ្វើការផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុតាមសំណើរបស់ភាគីឈ្នះក្តីបានឡើយ ។

ដើម្បីឱ្យការអនុវត្តន៍ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព ខ្ញុំសូមអស់លោក-លោកស្រី ជាប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី អនុវត្តតាមការណែនាំនេះឱ្យបានត្រឹមត្រូវ និង ផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់គ្រប់ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាល ស្រុក-ខណ្ឌ និង មន្ត្រីក្រោមឱវាទ ។

សូមលោក-លោកស្រី ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

អគ្គនាយក

លឹម វ៉ាន់

<u>ចម្លងជូន:</u>

- ក្រសួងយុត្តិធម៌
- គ្រប់សាលាខេត្ត-ក្រុង

"ដើម្បីសូមជូនជ្រាប"

- ឯកសារ-កាលប្បវត្តិ

អាសយដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងព្រលឹត ខ័ណ្ឌ ៧មករា ក្រុងភ្នំពេញ
Tel/Fax (855 23) 215 660, e-mail : mlmupc@Camnet.Com.Kh